ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ៩៩១ អ.ក
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ ៦០៨ ស.ស
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ១១៩៤ ជ.រ
ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ប
ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការ | ៖ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ១ ម៉ោង ៩ ព្រឹក។ |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ១ ម៉ោង ៩ ព្រឹក។ |

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

### ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

| | |
|---|---|
| លោក [redacted] | ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| លោក | ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា |
| លោក | ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា |

### តំណាងអយ្យការ

| | |
|---|---|
| លោក [redacted] | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល |

### ក្រឡាបញ្ជីសវនាការ

| | |
|---|---|
| លោក [redacted] | ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល |

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២០ ឆ្នាំ) សញ្ជាតិខ្មែរ មុខរបរមិនពិត។
ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល។
ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។
ឪពុកឈ្មោះ ណាក់ (រ) ម្ដាយឈ្មោះ [redacted] រឿន (រ) នៅលីវ។
ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] បញ្ញា ភេទប្រុស កើតឆ្នាំ២០០៤ (អាយុ ១៧ ឆ្នាំ) សញ្ជាតិខ្មែរ មុខរបរមិនពិត។
ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល។
ទីលំនៅភូមិលេ[redacted] ខេត្តកណ្ដាល។
ឪពុកឈ្មោះ [redacted] វាសនា (រ) ម្ដាយឈ្មោះ [redacted] ចន្ទ (រ) នៅលីវ។



Scanned with CamScanner

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេតត្តកណ្តាល។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាមដីកាដំណោះស្រាយលេខ ១០៧១ ដកដស (ខ)/២២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមាន៖**

## អង្គហេតុដែលប្តឹងមកតុលាការ

កាលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ២០ នាទី ស្ថិតនៅចំណុចផ្លូវលំចាក់បេតុង ភូមិលេខ២ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល សមត្ថកិច្ចចុះល្បាត ឃើញឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] **បញ្ញា** កំពុងជិះម៉ូតូមានការសង្ស័យ ភ្លាមនោះសមត្ថកិច្ចក៏បានឃាត់ខ្លួនសួរនាំ និងឆែកឆេររកថ្នាំញៀនចំនួន ០១ កញ្ចប់តូច នៅក្នុងហោប៉ៅរបស់ត្រូវចោទឈ្មោះ [redacted] បញ្ញា។ បន្ទាប់សមត្ថកិច្ចក៏ឃាត់ខ្លួនជនត្រូវចោទទាំងពីររួមនិងវត្ថុតាងមកអធិការដ្ឋានក្រុងតាខ្មៅ ដើម្បីចាត់ការតាមនីតិវិធី។ តាមចម្លើយរបស់ជនត្រូវចោទបានឆ្លើយថា ថ្នាំញៀននោះ បានទិញពីជនមិនស្គាល់ឈ្មោះក្នុងតម្លៃ ១៥.០០០ រៀល។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី**

អំពីវិវាទកម្មស្តីពីនិយតភាពនៃការរកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី**

**១. ការសួរចម្លើយជនជាប់ចោទ**

១.១. ចម្លើយជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ ខ្ញុំបាទបានសមត្ថកិច្ចនាំខ្លួនមកប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរលំព្រោះ ខ្ញុំបាទមានគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួនមួយកញ្ចប់ ដែលបានទុកហោប៉ៅអាវខាងឆ្វេង។ ថ្នាំញៀនមួយកញ្ចប់តូចនេះជារបស់ខ្ញុំទិញនៅម្តុំព្រែកស្តានតាំងហុង នៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ទិញក្នុងតម្លៃ ១៥.០០០ រៀល យកដើម្បីទៅប្រើប្រាស់ជាមួយឈ្មោះ [redacted] ទូច។ ហើយខ្ញុំបាទចេះប្រើប្រាស់គ្រឿងញៀនរយៈពេលពីខែមកហើយ។ ចម្លើយដែលខ្ញុំបាទឆ្លើយជាចម្លើយពិតទាំងអស់មិនមានការបង្ខិតបង្ខំ ឬគំរាមគំហែងនោះទេ។

១.២. ចម្លើយជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** ចំពោះមុខចៅក្រមស៊ើបសួរ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ២០ នាទី ស្ថិតនៅចំណុចផ្លូវលំចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល ខ្ញុំបាទបានទៅទិញថ្នាំញៀនតែម្នាក់ឯង ពីជនមិនស្គាល់ឈ្មោះម្នាក់នៅម្តុំព្រែកសំរោង ក្នុងតម្លៃ ១៥.០០០ រៀល រួចក៏ជិះម៉ូតូបន្តទៅឌុបមិត្តភក្តិឈ្មោះ [redacted] ទូច ភេទប្រុស អាយុ ២០ ឆ្នាំ ដើម្បីរកកន្លែងប្រើប្រាស់គ្រឿង



Scanned with CamScanner

ញៀននោះ ស្រាប់តែសមត្ថកិច្ចមានការសង្ស័យក៏បានឆែកឆេររកថ្នាំញៀនមួយកញ្ចប់នោះនៅក្នុងហោប៉ៅរបស់ខ្លួនតែម្តង។ ខ្ញុំបាទទិញថ្នាំញៀននោះចំនួន ២ ដង ពីជនមិនស្គាល់បានចំនួន ២ លើកមកហើយ ដោយក្នុងមួយដងក្នុងតម្លៃ ១៥.០០០ រៀល ពេលខ្ញុំទៅទិញអ្នកលក់ជាអ្នកដើរលើផ្លូវបេតុង យកមកប្រគល់ឱ្យ។ ដោយមុនពេលមកទិញខ្ញុំបាទស្គាល់ពីមិត្តភក្តិ ពេលនេះភ្លេចលេខរបស់គាត់ហើយ។ ហើយថ្នាំដែលខ្ញុំទិញមកនោះក្នុងបំណងយកមកប្រើប្រាស់តែប៉ុណ្ណោះ គ្មានបំណងយកមកលក់បន្តនោះទេ។ រូបខ្ញុំពុំដែលធ្លាប់ជាប់ទោសពីមុនទេ និងមិនធ្លាប់ជួញដូរគ្រឿងញៀនទេ។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀននោះរយៈពេល ២ ខែមកហើយ។ នៅពេលដែលទៅទិញថ្នាំញៀន ខ្ញុំទៅទិញតែម្នាក់ឯងទេ រួចក៏ឈ្មោះ [redacted] ទូច បានឆាតមក ហើយខ្ញុំក៏បានជិះម៉ូតូទៅយកវា ដើម្បីទៅប្រើប្រាស់គ្រឿងញៀននោះ។

**១.៣.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **ទូច** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ បាទដោយសារតែខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំមានទុកថ្នាំញៀនចំនួន ១ កញ្ចប់តូច ក្នុងហោប៉ៅ។ ខ្ញុំបាទបានចេះប្រើប្រាស់គ្រឿងញៀនរយៈពេល ២ ខែមកហើយ។ ថ្នាំញៀនមួយកញ្ចប់តូច នោះជារបស់មិត្តភក្តិខ្ញុំឈ្មោះ [redacted] **បញ្ញា** ភេទប្រុស ដែលបានទិញពីម្តុំព្រែកតាំងហ៊ុន ក្នុងតម្លៃ ១៥.០០០ រៀល។ កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១៖០០ នាទី ឈ្មោះ [redacted] **បញ្ញា** ភេទប្រុស ដែលត្រូវជាមិត្តភក្តិរបស់ខ្ញុំបានតេមកបបួលខ្ញុំប្រើប្រាស់គ្រឿងញៀន បន្ទាប់មកពួកយើងក៏នាំគ្នាទៅរកកន្លែងជក់ថ្នាំ លុះជិះទៅដល់ផ្លូវបេតុងភូមិលេខ៤ ក៏ត្រូវសមត្ថកិច្ចធ្វើការឆែកឆេររកឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់ និងវត្ថុប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត។

**១.៤.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **ទូច** ចំពោះមុខចៅក្រមស៊ើបសួរ នៅថ្ងៃទីកើតហេតុវេលាម៉ោង ៩ យប់ ខ្ញុំបាទកំពុងដេកនៅផ្ទះ ស្រាប់តែឈ្មោះ [redacted] **បញ្ញា** បានឆាត និងខលមកខ្ញុំបបួលទៅប្រើប្រាស់គ្រឿងញៀនពេលនោះ ខ្ញុំក៏បានចុះទៅខាងក្រោម និងរងចាំអស់រយៈពេល ១០ នាទី ឈ្មោះ [redacted] **បញ្ញា** ក៏បានមកដល់ រួចបន្តទៅលាងម៉ូតូ ហើយជិះម៉ូតូទៅកន្លែងប្រើប្រាស់គ្រឿងញៀននោះ តែមិនទាន់ប្រានប្រើប្រាស់ផង ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ ខ្ញុំសូមបញ្ជាក់ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅក្នុងខ្លួនរបស់ខ្ញុំ ពុំមានគ្រឿងញៀនទេ គ្រឿងញៀនដែលសមត្ថកិច្ចរកឃើញ គឺនៅនឹងខ្លួនរបស់ឈ្មោះ [redacted] **បញ្ញា** ខ្ញុំមិនបានរក្សាទុកនូវគ្រឿងញៀនសម្រាប់ការប្រើប្រាស់នោះទេ។ ខ្ញុំបាទទើបតែចេះប្រើប្រាស់គ្រឿងប៉ុណ្ណោះ។ កន្លងមកខ្ញុំពុំដែលបានសមត្ថកិច្ចហៅទៅអប់រំ ឬប្រព្រឹត្តអំពើជួញដូរថ្នាំញៀនអ្វីទេ។

### សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** អវត្តមាននាពេលសវការ។

២. ជនជាប់ចោទឈ្មោះ [redacted] **ទូច** អវត្តមាននាពេលសវការ។

**ខ. សេចក្តីសន្និដ្ឋាន៖**

**២. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពេលដែលលាបនស្តាប់កិច្ចពិភាក្សាដេញដោលរួចមក និងពិនិត្យរបាយការណ៍សមត្ថកិច្ច ឃើញថាមានភាពស៊ីចង្វាក់គ្នាអាចឱ្យតំណាងអយ្យការរក្សាការចោទប្រកាន់ទុកជាបានការដដែល។ តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចតាមច្បាប់។



Scanned with CamScanner

**៤. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

ក្រោយពេលដែលបានស្ដាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា កូនក្ដីរបស់ខ្ញុំបាទបានសារភាពពីទោសកំហុសរបស់ខ្លួនហើយ ដូច្នេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្ញុំបាទសូមឱ្យតុលាការជួយបន្ធូបន្ថយទោសដល់កូនក្ដីខ្លួនផង។

*- ក្រោយពីបាន ស្ដាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្ដាប់សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្ដី**

សាលាដំបូងខេត្តកណ្ដាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **៩៩១ អ.ក** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ទូច** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ និងឈ្មោះ [redacted] **បញ្ញា** ភេទប្រុស កើតឆ្នាំ២០០៤ (អាយុ ១៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំណុចចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្ដឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** និងឈ្មោះ [redacted] **ទូច**៕

**គ. អំពី ពិរុទ្ធភាព**

**១.** តាមចម្លើយជនជាប់ចោទនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខតំណាងអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរ រួមទាំងសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ និងភស្តុតាងផ្សេងៗ បង្ហាញថា អង្គហេតុដែលប្ដឹងមកតុលាការពិតជាកើតឡើងយ៉ាងពិតប្រាកដ។ ហេតុនេះ ការណ៍ដែលអង្គហេតុដែលប្ដឹងមកតុលាការ ត្រូវបានទទួលស្គាល់អង្គហេតុដែលប្ដឹងមកតុលាការ តុលាការនឹងបន្តការពិនិត្យវាយតម្លៃ និងផ្ទៀងផ្ទាត់រវាងអង្គហេតុ និងបទចោទប្រកាន់ដែលមានលើជនជាប់ចោទ។

**២.** តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ទូច** និងឈ្មោះ [redacted] **បញ្ញា** បំពេញធាតុសត្យានុម័តនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំណុចចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**៣.** តាមសំអាងហេតុចំណុចទី១ ដល់ទី២ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ទូច** និងឈ្មោះ [redacted] **បញ្ញា** បំពេញធាតុអត្តនោម័តនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវ**



Scanned with CamScanner

**សាធាតុញៀន** ប្រព្រឹត្តនៅភូមិចំណុចចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ។

៤. តាមសំអាងហេតុចំណុចទី១ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ទូច និងឈ្មោះ [redacted]បញ្ញា បំពេញធាតុអត្តនោម័តនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន** ប្រព្រឹត្តនៅភូមិចំណុចចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] បញ្ញា បានបំពេញធាតុផ្សំនៃបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន** និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ទូច និងឈ្មោះ [redacted] បញ្ញា មានពិរុទ្ធភាពពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន** ប្រព្រឹត្តនៅភូមិចំណុចចាក់បេតុងភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការនឹង



Scanned with CamScanner

សម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារ តាមមាត្រា ២៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

១. ឈ្មោះ [redacted] **ទូច** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៦ **(ប្រាំមួយ) ខែ** ប៉ុន្តែទោសដាក់ពន្ធនាគារត្រូវព្យួរធម្មតាទាំងស្រុង ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះតាមស្ថានភាពនៃការប្រើប្រាស់នូវសារធាតុញៀននេះ ឃើញថា ជនជាប់ចោទគប្បីទទួលទោសខាងលើ ប៉ុន្តែតាមរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ឃើញថា មានភាពធូរស្រាលចំពោះការផ្តាច់ចោលនូវសារធាតុញៀនរបស់ជនជាប់ចោទ ហេតុនេះ តុលាការសម្រេចព្យួរទោសខាងលើនេះ ធម្មតាទាំងស្រុង។

២. ឈ្មោះ [redacted] បញ្ញា ភេទប្រុស កើតឆ្នាំ២០០៤ (អាយុ ១៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៣ **(បី) ខែ** ប៉ុន្តែទោសដាក់ពន្ធនាគារត្រូវព្យួរធម្មតាទាំងស្រុង ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះតាមស្ថានភាពនៃការប្រើប្រាស់នូវសារធាតុញៀននេះ ឃើញថា ជនជាប់ចោទគប្បីទទួលទោសខាងលើ ប៉ុន្តែតាមរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ឃើញថា មានភាពធូរស្រាលចំពោះការផ្តាច់ចោលនូវសារធាតុញៀនរបស់ជនជាប់ចោទ ហេតុនេះ តុលាការសម្រេចព្យួរទោសខាងលើនេះ ធម្មតាទាំងស្រុង។

**គ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

**ឃ. អំពី វត្ថុចាប់យក**

តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញថា វត្ថុចាប់យកដែលរួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីន ចំនួន ១ (មួយ) កញ្ចប់តូច និងម៉ូតូចំនួន ០១ គ្រឿង ម៉ាក វេវ ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1FJ-3396 ដែលត្រូវបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] **ទូច** គឺជាឧបករណ៍ សម្ភារៈ វត្ថុដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស និងជាវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។ ហេតុដូច្នេះ តុលាការនឹងសម្រេចរឹបអូសវត្ថុចាប់យកទាំងអស់ដែលបានចាប់យក។

## សេចក្តីសម្រេច

**ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] ទូច ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ឈ្មោះ [redacted] បញ្ញា ភេទប្រុស កើតឆ្នាំ២០០៤ (អាយុ ១៧ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ



Scanned with CamScanner

ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ. ផ្ដន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] ទូច ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៦ **(ប្រាំមួយ) ខែ** ប៉ុន្តែទោសដាក់ពន្ធនាគារត្រូវព្យួរធម្មតាទាំងស្រុង ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ឈ្មោះ [redacted] បញ្ញា ភេទប្រុស កើតឆ្នាំ២០០៤ (អាយុ ១៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៣ **(បី) ខែ** ប៉ុន្តែទោសដាក់ពន្ធនាគារត្រូវព្យួរធម្មតាទាំងស្រុង ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្លូវលំបេតុង ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

គ. វត្ថុចាប់យកដែលរួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីនចំនួន ១ (មួយ) កញ្ចប់តូច និងម៉ូតូចំនួន ១ គ្រឿង ម៉ាក វេវ ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1FJ-3396 ត្រូវរឹបអូស។

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈកំបាំងមុខជនជាប់ជាប់។*

*សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈនៅថ្ងៃ អង្គារ ១៤ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ៩ ព្រឹក នៅសាលសវនាការលេខ ១។*

*ភាគីដែលមានបំណងធ្វើបណ្ដឹងទាស់ ឬបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។*

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

**ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ អង្គារ ១៤ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្ដាល ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner